ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚ ✣ ៚

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៦១០ អយក.ប្រក

# ប្រកាស
## ស្តីពី ការបើកសាលាបឋមសិក្សា អន្លង់តាសេកក្រោម ជាសាលាបឋមសិក្សា ពេញលក្ខណៈ

---

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតរបស់ គណៈកម្មការសាងសង់សាលាបឋមសិក្សា អន្លង់តាសេកក្រោម ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ ដោយមានចំណារឯកភាពរបស់មន្ទីរ អប់រំយុវជន និង កីឡា ខេត្ត កណ្តាល ចុះថ្ងៃទី ២២ខែ សីហា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

### សំរេច

<u>ប្រការ១</u> : បើកសាលាបឋមសិក្សា **អន្លង់តាសេកក្រោម** ដែលមានទីតាំងស្ថិតនៅភូមិ **អន្លង់តាសេកក្រោម** ឃុំ **ព្រែកអំបិល** ស្រុក **ស្អាង** ខេត្ត **កណ្តាល** ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

<u>ប្រការ២</u> : សាលាបឋមសិក្សា **អន្លង់តាសេកក្រោម** ត្រូវដឹកនាំដោយ នាយក១រូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

<u>ប្រការ៣</u> : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

<u>ប្រការ៤</u> : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **ស្រុកស្អាង** នាយកសាលាបឋមសិក្សា **អន្លង់តាសេកក្រោម** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី២៦ ខែ៦ ឆ្នាំ ២០០៣
ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាខេត្ត កណ្តាល

<u>ដើម្បីជូនជ្រាបជាពត៌មាន</u>

-ដូចប្រការ ៤
-កាលប្បវត្តិ-ឯកសារ នា បស